

# ដើមកន្ទុំថេត ជាវត្ថុធាតុដើមសម្រាប់ផលិតថាមពលអគ្គិសនីជីវម៉ាស

*ដោយរដ្ឋបាលព្រៃឈើ*

ជីវម៉ាសដែលប្រើប្រាស់ជាប្រភេទឥន្ធនៈ បានមកពីប្រភពជាច្រើនផ្សេងៗគ្នា និង អាចយកទៅប្រើប្រាស់បានច្រើនរបៀប ដោយដំឡើងជាអគ្គិសនី ឧស្ម័ន កម្ដៅ ឬគ្រឿងឥន្ធនៈរាវ ហើយក៏សំដៅទៅលើឥន្ធនៈដែលមានសារធាតុកាបូនណឹត កាត់បន្ថយនូវឧស្ម័នកាបូនិក ប្រសិនបើត្រូវបានគេយកទៅប្រើប្រាស់ជំនួសប្រេងឥន្ធនៈ និងមានសារធាតុស៊ុលហ្វួរតិចតួចបំផុតធៀបទៅនឹងការប្រើប្រាស់ធ្យូង និង ប្រេង ។ ជាងនេះទៅទៀតវាជាប្រភពធនធានក្នុងស្រុកដែលផ្ដល់ថាមពលបានយូរអង្វែង និងជាប្រភពកកើតឡើងវិញ ដែលមានអត្ថប្រយោជន៍ខ្លាំងក្នុងអត្ថន័យសិក្សាបច្ចេកទេស និង សេដ្ឋកិច្ចក្នុងប៉ុន្មានទសវត្សខាងមុខនេះ ។ បច្ចុប្បន្ន ថាមពលជីវម៉ាសត្រូវបានគេចាត់ទុកថាជាប្រភពថាមពលសម្រាប់អភិវឌ្ឍ និងសម្រាប់ប្រើប្រាស់ក្នុងវិស័យឧស្សាហកម្មនាពេលអនាគតផងដែរ ។

ថាមពលជីវម៉ាស កំពុងត្រូវបានគេយកចិត្តទុកដាក់ពីវិស័យឯកជនក៏ដូចគម្រោងមួយចំនួនរបស់រាជរដ្ឋាភិបាល ស្របពេលដែលតម្លៃប្រេងឥន្ធនៈនៅលើទីផ្សារមានការកើនឡើងយ៉ាងខ្ពស់ ។ ការយល់ដឹងពីបច្ចេកទេស និង បច្ចេកវិទ្យាក្នុងការបម្លែង ក៏ដូចជាអត្ថប្រយោជន៍នៃបរិស្ថាន និងតម្លៃធនធានធម្មជាតិ កាន់តែក្លាយជាចំណុចជាទីចាប់អារម្មណ៍ខ្លាំងឡើងៗ ។ប្រភពជីវម៉ាសមួយចំនួនដែលត្រូវយកទៅកែច្នៃសម្រាប់បង្កើតជាថាមពលមានដូចជា កាកអំពៅ, ចំបើង, អង្កាម, ត្រឡោកដូង, សំបកគ្រាប់ស្វាយចន្ទី សំណល់រឹងផ្សេងៗ ( អាចដុតឆេះ) មួយចំនួននៅតាមទីក្រុង ឬទីប្រជុំជន សំណល់លាមកសត្វ និងដើមកន្ទុំថេត ។ល ។ តទៅនេះយើងនឹងលើកយកពីជីវម៉ាសដែលមានប្រភព ពីដើមកន្ទុំថេត ដែលត្រូវប្រើប្រាស់ជាប្រភពផ្ដល់ថាមពលមកធ្វើ អត្ថាធិប្បាយ ។

ដើមកន្ទុំថេត គឺជាប្រភេទជីវម៉ាសមួយបែប ដែលអាចបំពេញមុខងារតម្រូវការក្នុងការផ្គត់ផ្គង់ថាមពលនៅតាមជនបទ ។ វាមិនត្រឹមតែជួយដល់ការកាត់បន្ថយនូវសម្ពាធទៅលើធនធានធម្មជាតិព្រៃឈើតែម្យ៉ាងនោះទេ ប៉ុន្តែវាអាចជួយបង្កើន និងស្ដារនូវស្ថានភាពគុណភាពដីអន់ ឱ្យបានកាន់តែប្រសើរឡើង ក៏ដូចជាផ្ដល់ជាប្រភពថាមពលសម្រាប់ដាំស្ល និង ជាពិសេសសម្រាប់យកទៅកែច្នៃផលិតជាថាមពលអគ្គិសនីប្រើប្រាស់ដើម្បីជួយបង្កើតមុខ របរសម្រាប់បង្កើនចំណូលក្នុងគ្រួសារ និងផ្ដល់ជាចំណីសត្វ ។ល ។

ដើមកន្ទុំថេត ពីមុនគេធ្លាប់ស្គាល់ថា គ្រាន់តែជាប្រភេទរុក្ខជាតិក្នុងស្រុកដ៏សាមញ្ញមួយបែបដែលគេដាំនៅតាមព្រំដី ឬផ្ទះ និងយកត្រួយសម្រាប់ធ្វើជាអន្លក់ ឬបន្លែល្បាយនំបញ្ចុក ហើយដើមវាសម្រាប់ធ្វើជាអុសដុតដាំស្ល ។ ប៉ុន្តែបច្ចុប្បន្ន វាត្រូវបានគេយកទៅបើប្រាស់ក្នុងគោលបំណងផលិតឧស្ម័នសម្រាប់ដំណើរការម៉ាស៊ីនភ្លើងផលិតអគ្គិសនីដែលពុំធ្លាប់មានពីមុនមក និងពុំនឹកស្មានដល់ ។ ទាំងផ្នែកភូមិសាស្ត្រ ប្រភេទដី ព្រមទាំងលក្ខខណ្ឌជីវភាពប្រជាសហគមន៍នៅឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង មានលក្ខណៈសមស្របក្នុងការទទួលយកនូវប្រភពថាមពលបែបថ្មីនេះ ។

សហគមន៍អគ្គិសនីជនបទដែលមានទីតាំងស្ថិតនៅក្នុងភូមិអន្លង់តាម៉ី ឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង មានចម្ងាយប្រមាណ១៨-១៩ គ.ម ភាគនិរតីនៃទីរួមខេត្ត បានបង្កើត



ស្លឹក និងដើមកន្ទុំថេត





ផ្លែកន្ទុំថេត

ឡើងក្នុងឆ្នាំ ២០០៤ ដោយមានច្បាប់អនុញ្ញាតពីក្រសួងមហាផ្ទៃ និង ការទទួលស្គាល់ពីអាជ្ញាធរអគ្គិសនីកម្ពុជាក្នុងឆ្នាំ ២០០៥។ សហគមន៍អគ្គិសនីជនបទនេះ បានបង្កើតសិប្បកម្មអគ្គិសនីខ្នាតតូច ដំណើរការដោយប្រព័ន្ធជីវម៉ាស ដោយប្រើប្រាស់ប្រភពថាមពល ពីដើមកន្ទុំថេត។

លោក **សំ សោភ័ណ** ដែលជាអនុប្រធានគណៈកម្មាធិការសហគមន៍ បានបង្ហើបឱ្យដឹងថា សហគមន៍របស់លោក ដែលមានប្រជាជន ៧០ គ្រួសារ ដោយមើលឃើញជាក់ស្ដែងពីតម្រូវការអគ្គិសនីសម្រាប់ប្រើប្រាស់ បានព្រមព្រៀងគ្នាបង្កើតគម្រោងនេះឡើង ដោយមានការគាំទ្រជាគំនិត និងបច្ចេកទេសពីអង្គការអេស អិន អ៊ី កម្ពុជា ដែលបានលើកគម្រោងឡើងដើម្បីផ្ដត់ផ្គង់អគ្គិសនីដោយថាមពលកកើតឡើងវិញដល់សហគមន៍ ក្រោមជំនួយឧបត្ថម្ភពីមូលនិធិកាណាដា ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិនិង គ្រប់គ្រងដោយសហគមន៍ខ្លួនឯងដោយផ្ទាល់។ បច្ចេកវិទ្យាផលិតឧស្ម័នដោយថាមពលជីវម៉ាសនេះ អាចប្រើប្រាស់ក្នុងការបម្លែងឧស្ម័នពីឥន្ទនៈ អុសសម្រាប់បញ្ឆេះម៉ាស៊ីនភ្លើង ផលិតថាមពលអគ្គិសនី ។ ចំណាយផ្សេងៗទាក់ទងនឹងការបំពាក់ឧបករណ៍គ្រឿងចក្រដើរដោយថាមពលជីវម៉ាស់ និងម៉ាស៊ីនភ្លើង ព្រមទាំងប្រព័ន្ធបែងចែកគឺជាជំនួយឥតសំណង។ ទាំងប្រព័ន្ធគ្រប់គ្រងដំណើរការ និង ទំហែទាំជាភារកិច្ចអនុវត្តដោយសហគមន៍ខ្លួនឯងផ្ទាល់។

ម៉ាស៊ីនបំពាក់ក្នុងជំហានដំបូង គឺមានម៉ាស៊ីនភ្លើងកំលាំង ១៥គ.វ៉.អំពែរនិងមានប្រសិទ្ធភាព៧គីឡូវ៉ាត់លើដំណើរការថេរ សម្រាប់ផ្គត់ផ្គង់សហគមន៍ចំនួន ៧០ គ្រួសារ និង អំពូលបំភ្លឺតាមផ្លូវចំនួន ២០ អំពូល។ ដោយឡែកបច្ចុប្បន្ននេះ សហគមន៍បានទទួលម៉ាស៊ីនដែលមានកម្លាំងរហូតដល់ទៅ ២៥ គ.វ៉ ពីអង្គការកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ដែលអាចបម្រើសេវាផ្គត់ផ្គង់អគ្គិសនីជូនដល់សមាជិកសហគមន៍ចំនួន ២៥០ គ្រួសារ។

**ប្រតិបត្តិការម៉ាស៊ីនភ្លើងដំណើរការដោយប្រព័ន្ធជីវម៉ាស**

លោក **សឿម ឆក** ដែលជាអ្នកបច្ចេកទេសក្នុងសហគមន៍អគ្គិសនីជនបទ បានប្រាប់ឱ្យដឹងពីដំណើរការក្នុងរោងសិប្បកម្មខ្នាតតូចនេះថា ដើមកន្ទុំថេតត្រូវបានគេដុតក្នុងឡមួយគ្រឿងដែលអាចផ្ទុកបានវត្ថុធាតុដើមនេះចំណុះ ២០០ គ.ក្រ និង អាចផ្ដល់ថាមពលប្រើប្រាស់ក្នុងរយៈពេល ៦-៧ ម៉ោង។ ឡដុតនេះត្រូវបានតភ្ជាប់ទៅកាន់ធុងចម្រោះឧស្ម័ន ៤ គ្រឿង រួមមានធុង តម្រងអង្កាម ១ គ្រឿង ធុងតម្រងអាចម៍រណា ២ គ្រឿង និងធុងមួយទៀតប្រើតម្រងក្រណាត់កូតុង ដែលជាតម្រងចុងក្រោយសម្រាប់បន្សុតឧស្ម័នមុននឹងទៅដល់ ម៉ាស៊ីនភ្លើង ។ វត្ថុធាតុដើមកន្ទុំថេតត្រូវបានដាក់ចូលក្នុងម៉ាស៊ីន កាត់ជាកង់ៗមានប្រវែងប្រហែល ៥-៦ ស.ម រួចហាលឱ្យស្ងួតមុននឹងចាក់ចូលទៅក្នុងឡដុតយកចំហាយ

ឧស្ម័ន ។

បច្ចេកទេសដើរដោយប្រព័ន្ធជីវម៉ាសនេះ ត្រូវបានបង្កើតឡើងដោយក្រុមហ៊ុន Ankur Scientific Energy Technologies Pvt.Ltd Baroda, ប្រទេសឥណ្ឌា ។ យោងតាមរបាយការណ៍ស្តីពី



រោងម៉ាស៊ីនភ្លើងអគ្គិសនីជីវម៉ាស

បច្ចេកវិទ្យានេះ បង្ហាញឱ្យឃើញថា ក្នុងបរិមាណធនធានជីវម៉ាសនេះពី ១,២-១,៥ គ.ក្រ ( សំណើមតិចជាង ២០% ) អាចផលិតថាមពលអគ្គិសនីបាន ១ គ.វ.ម៉ ។ បានន័យថាក្នុងមួយតោនជីវម៉ាស (ដើមកន្ទុំថេត) អាចបម្លែងបានថាមពលអគ្គិសនីបានប្រមាណ ៧១៤ គ.វ.ម៉ ។

សម្រាប់ដំណើរការផលិតកម្មនៅក្នុងសិប្បកម្មផលិតអគ្គិសនីនេះ លោក សោភ័ណ មានប្រសាសន៍ថា លោកមានកម្លាំងពលកម្មចំនួន ៤ នាក់ ក្នុងនោះ ២ នាក់ធ្វើការពេលថ្ងៃ និង ២ នាក់ទៀតសម្រាប់ពេលយប់ ប៉ុន្តែលោកគណៈកម្មការសហគមន៍ដែលមានតួនាទីមើលការខុសត្រូវរួមចំនួន ៥ រូប ។ ទាក់ទងនឹងហេតុផលដែលនាំឱ្យសហគមន៍ប្រើប្រាស់ដើមកន្ទុំថេតជាវត្ថុធាតុដើម ក្នុងការផលិតថាមពលអគ្គិសនីនេះ លោកអនុប្រធានបានប្រាប់ឱ្យដឹងថា ដើមនេះវាងាយក្នុងការដាំដុះ និងឆាប់បានទទួលផល និង ងាយរកបានជាងប្រភពជីវម៉ាសដទៃទៀត ហើយវាក៏មានលក្ខណៈសមស្រប សម្រាប់លក្ខខណ្ឌប្រភេទដីនៅក្នុងតំបន់សហគមន៍ផងដែរ ក្រៅពីផ្តល់ថាមពល និងផ្តល់កម្រៃផ្នែកសេដ្ឋកិច្ចបានខ្ពស់ ។ល។

ដោយមានគំនិតផ្តួចផ្តើមពីអង្គការ SNE Cambodia សហគមន៍ត្រូវបានណែនាំ និង ផ្តល់កូនដើមកន្ទុំថេតជូនសម្រាប់ដាំដុះតាំងពីឆ្នាំ ២០០៤ មុនពេលដែលសហគមន៍អគ្គិសនីកកើតឡើងម្ល៉េះ ។ ក្នុងរយៈពេលប្រហែលជា១ឆ្នាំកន្លះដំបូង សហគមន៍អាចកាប់មែកវាបាន និងទុកឱ្យវាដុះលូតលាស់បែកមែក ប្រហែលជាកន្លះឆ្នាំក្រោយមកទៀតអាចកាប់វាជាបន្ត ។

## តម្លៃប្រតិបត្តិការ

តម្លៃដើមកន្ទុំថេតមានសំណើមរហូតដល់ជិត ៤០% ទិញចូលក្នុង ១ តោនគឺ ១២ ដុល្លារ ឯតម្លៃស្ងួតគឺមានចន្លោះពី ២០ ទៅ ២៥ ដុល្លារសហរដ្ឋអាមេរិក ។ ដោយសហការជាមួយគ្នាទៅវិញទៅមក បច្ចុប្បន្នសមាជិកសហគមន៍ជាអ្នកផ្តល់វត្ថុធាតុដើមដល់សហគមន៍អគ្គិសនីជនបទ ដោយលក់ក្នុងតម្លៃដូចខាងលើ ឯសហគមន៍អគ្គិសនីជនបទលក់ថាមពលអគ្គិសនីដែលផលិតបានជូនដល់សមាជិកសហគមន៍ក្នុងតម្លៃមួយយ៉ាងទាប បើប្រៀបធៀបទៅនឹងតម្លៃដែលផ្តល់ដោយប្រភពសេវាកម្មដំណើរការដោយម៉ាស៊ីនភ្លើងប្រេងឥន្ធនៈ ។ ក្នុងនេះតម្លៃលក់ចេញអគ្គិសនីឱ្យសហគមន៍គឺ ១៥០០ រៀល ក្នុង ១ គ.វ.ម៉ ( ខុសគ្នាបួនដង បើធៀបទៅនឹងតម្លៃអ្នកដែលនៅក្រៅសហគមន៍ គឺ ៦០០០ រៀល ក្នុង ១ គ.វ.ម៉ ។ តម្លៃលក់នេះគឺផ្អែកទៅតាមបរិមាណប្រើប្រាស់ជាក់ស្តែង ( លេខកុងទ័រ) និងរួមបញ្ចូលតម្លៃប្រតិបត្តិការ តម្លៃថែរក្សា ក៏ដូចជាតម្លៃរំលស់ទៅលើឧបករណ៍ គ្រឿងបរិក្ខានៅក្នុងសហគមន៍អគ្គិសនីជនបទ ។

ដោយឡែកអត្រាថ្លៃដើម ( ថ្លៃផលិតថាមពលក្នុង ១ គីឡូវ៉ាត់ ) ផលិតអគ្គិសនីដើរដោយចំហេះឧស្ម័នពីវត្ថុធាតុដើមនៃដើមកន្ទុំថេត ថោកជាងអត្រាថ្លៃដើមដែលផលិតថាមពលដោយម៉ាស៊ីនភ្លើងប្រើប្រេងម៉ាស៊ូតចំនួន ៦ ដង ។ មានន័យថា ដើម្បីផលិតថាមពលអគ្គិសនីបាន ១ គ.វ.ម៉ គេត្រូវចំណាយប្រេងម៉ាស៊ូត ០.៣ លីត្រ អស់តម្លៃប្រហែល ០.២០-០.៣០ ដុល្លារ ( អាស្រ័យលើម៉ាស៊ីនភ្លើងចាស់ ឬថ្មី ឬប្រភេទវា) ប៉ុន្តែគេចំណាយត្រឹមតែ ០.០៣៥ដុល្លារប៉ុណ្ណោះ សម្រាប់ផលិតថាមពលអគ្គិសនីដោយប្រើឧស្ម័នពីវត្ថុធាតុដើមនេះ ។

## ផលប្រយោជន៍ដែលសហគមន៍ទទួលបាន

ប្រៀបធៀបការប្រើប្រាស់ម៉ាស៊ីនភ្លើងដំណើរការដោយប្រព័ន្ធជីវម៉ាសជាមួយនឹងម៉ាស៊ីនភ្លើងដំណើរការដោយប្រេងឥន្ធនៈ លោក សោភ័ណ បញ្ជាក់ថា វាផ្តល់ផលចំណេញច្រើនណាស់ ក្នុងផ្នែកសេដ្ឋកិច្ច និង វាជួយកាត់បន្ថយការនាំប្រេងឥន្ធនៈពីក្រៅប្រទេស និង ជួយបង្កើនជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋទៀតផង ទាំងការរកចំណូលបន្ថែមក្នុងគ្រួសារក្រៅពីការធ្វើកសិកម្មប្រចាំរដូវរបស់ខ្លួន ។ សម្រាប់ផ្នែកបរិស្ថាន វាជាប្រភេទម៉ាស៊ីនដែលមិនមានផ្សែងបំពុល ហើយសមាជិកសហគមន៍ភាគ

ច្រើនមិនចាំបាច់ចូលទៅក្នុងព្រៃកាប់ឈើសម្រាប់ធ្វើជាអុសដុតទៀតនោះទេ គឺពួកគាត់អាចប្រើប្រាស់ដើមកន្ទុំថេតដែលសល់ពីលក់តែម្តង។ សមាជិកសហគមន៍មួយចំនួនដែលបានសម្ភាសន៍បានថ្លែងថា ចាប់តាំងពីមានដំណើរការសហគមន៍អគ្គិសនីជនបទនេះមក សហគមន៍មានការផ្លាស់ប្តូរមុខមាត់ថ្មី ដោយទទួលបានទាំងអគ្គិសនីសម្រាប់ការបំភ្លឺក្នុងផ្ទះ ទាំងការអប់រំ និងព័ត៌មានកំសាន្តផ្សេងៗ តាមរយៈវិទ្យុ និងទូរទស្សន៍។ សមាជិកសហគមន៍មួយចំនួននៅតាមដងផ្លូវមានគម្រោងនឹងបើកកន្លែងរកស៊ីឬហាងលក់ដូរតូចតាចក្នុងខណៈដែលពួកគាត់មានភ្លើងអគ្គិសនីសម្រាប់ប្រើប្រាស់។

សហគមន៍អគ្គិសនីជនបទចង់ពង្រីកសមាជិករបស់ខ្លួនបន្តទៀតដែរ ដើម្បីអាចឱ្យប្រជាជនក្នុងតំបន់របស់ខ្លួនទាំងអស់អាចមានលទ្ធភាពប្រើប្រាស់ថាមពលបានគ្រប់ៗគ្នា ប៉ុន្តែកម្លាំងផលិតកម្មរបស់ខ្លួននៅមានកម្រិតកំណត់ ។

តាមវិទ្យុសម្លេងអាស៊ីសេរី ផ្សាយចេញពីទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក នាខែកុម្ភៈ ឆ្នាំ ២០០៩ ដែលជាកិច្ចសម្ភាសន៍របស់អ្នកស្រី កេសរ វុទ្ធីយ៉ា បានឱ្យដឹងថា ....សមាជិកគណៈកម្មការនៃសហគមន៍អគ្គិសនីជនបទ លោក ឌួង លី បានឱ្យដឹងថា ឃុំឈើទាលស្ថិតនៅប្រមាណតែ ១៨ គ.ម ប៉ុណ្ណោះពីទីរួមខេត្តបាត់ដំបង តែពុំមានបណ្តាញភ្លើងអគ្គិសនីរដ្ឋ ឬ ឯកជនតភ្ជាប់ទៅដល់នោះឡើយ ។ ចំពោះដំណើរការនៃម៉ាស៊ីនផលិតភ្លើងអគ្គិសនីជីវម៉ាសរបស់សហគមន៍វិញ លោក ឌួង លី បានបញ្ជាក់ថា ក្នុងមួយខែៗគឺត្រូវការអុសពីដើមកន្ទុំថេតចំនួនជិត ១ តោន ដែលអ្នកភូមិបានដាំនៅតាមផ្ទះ ឬស្រែ ចំការហើយកាប់យកមកលក់ ។ " សមាជិកនៅក្នុងសហគមន៍អន្លង់តាមី បានដាំដើមកន្ទុំថេតដោយឥតបង្ខំដើម្បីលក់ជូនសហគមន៍ ហើយសហគមន៍បានផ្តល់មកវិញ នូវអគ្គិសនី។ នេះជាគោលការណ៍ចម្បងណាស់ដែលសមាជិកធ្វើការឱ្យសហគមន៍ ហើយសហគមន៍ បានផ្តល់ផលប្រយោជន៍ដល់សមាជិកវិញ " ។ លោក ឌួង លី ដែលជាតំណាងសហគមន៍ អន្លង់តាមី បានបញ្ជាក់បន្ថែមទៀតថា សព្វថ្ងៃនេះប្រជាជនចំនួន ៣០០ គ្រួសារ ក្នុងឃុំឈើទាលមានភ្លើងអគ្គិសនីប្រើប្រាស់បំភ្លឺផ្ទះសំបែង ថ្នាក់រៀន និងប្រកបមុខរបរផ្សេងៗចិញ្ចឹមជីវិត។ " តាំងពីយើងមានភ្លើងអគ្គិសនីប្រើប្រាស់មក យើងឃើញថាមានការរីកចម្រើនច្រើន ទាំងផ្នែកអប់រំ អាជីវកម្មតូចតាច នៅក្នុងភូមិ ដូចជា សិស្សានុសិស្សមានភ្លើងរៀន ប្អូនស្រីៗដែលរៀនចំណេះដឹង ផ្នែកអ៊ុតសក់ កាត់សក់ ធ្វើក្រចកអីហ្នឹង អាចយកចំណេះដឹងទាំងហ្នឹងមកបម្រើការនៅក្នុងភូមិ ប្រកបអាជីវកម្មចិញ្ចឹមជីវិតបាន "។ តាមឯកសាររបស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាក៏បានបញ្ជាក់ដែរថាទិសដៅសំខាន់ក្នុងការបង្កើតគម្រោងសហគមន៍អគ្គិសនីជនបទនេះ គឺសំដៅផលិតភ្លើងអគ្គិសនីដោយសារការដុតដើមកន្ទុំថេតនេះ ដើម្បីតភ្ជាប់បណ្តាញអគ្គិសនីជូនប្រជាពលរដ្ឋនៅតាមជនបទដែលនេះគឺជាមធ្យោបាយដែលមានលទ្ធភាពបង្កើតសហគ្រាសអាជីវកម្មមុខរបរតូចតាច ដែលនឹងជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់អ្នកភូមិក្នុងសហគមន៍ ។

...អុសសម្រាប់ផ្គត់ផ្គង់គឺត្រូវមានទំហំប៉ុនកដៃ ហើយត្រូវកាត់ជាកង់ៗ វែងបំផុតត្រឹម១០ ស.ម ហើយហាលឱ្យស្ងួតក្នុងកម្រិតពី ១៤-២០ អង្សា មុននឹងទៅដាក់តម្រៀបក្នុងឡម៉ាស៊ីនភ្លើង។

នៅក្នុងដំណាក់កាលនៃការដុតអុសទាញយកឧស្ម័នដើម្បីអូសម៉ាស៊ីនភ្លើងជីវម៉ាស ការថែទាំភ្លើងដោយដាក់អុសបន្ថែមចូលទៅក្នុងឡឱ្យបានទៀងទាត់រហូតជាកត្តាសំខាន់ណាស់ ដើម្បីធានាឱ្យបានឧស្ម័នគ្រប់គ្រាន់សម្រាប់ផលិតចេញជាថាមពលអគ្គិសនីតាមសេចក្តីត្រូវការ។ លោក អ៊ុន រឿន អ្នកជំនាញអង្គការ SNE Cambodia ដែលជួយគាំទ្រផ្នែកបច្ចេកទេស និងគ្រប់គ្រង ដល់គម្រោងសហគមន៍អគ្គិសនីជនបទនៅអន្លង់តាមី បានគូសបញ្ជាក់បន្ថែមទៀតអំពីដំណើរការផលិតភ្លើងអគ្គិសនីជីវម៉ាសនេះ បន្ទាប់ពីដំណាក់កាលមានអុសដំណើរការក្នុងឡរួចហើយនោះ ។ "បើតាមរូបវិន្តនៃវិទ្យាសាស្ត្រវិញ តើហេតុអ្វីបានជាឧស្ម័នអាចរត់ជំនួសប្រេង? នៅក្នុងកម្មវិធីគីមី ដែលចំហេះឆេះនៅក្នុងឡ គឺថា កាលណាវាឆេះ វាចាប់ផ្តើមកំដៅពី ២០០ ទៅ ៨០០ អង្សា ហើយនៅក្នុងចំហេះនេះមានជាតិអ៊ីដ្រូហ្សែន មានអុកស៊ីហ្សែន មានអាសូត និងមានកាបូនម៉ូណូអុកស៊ីត និងកាបូនឌីអុកស៊ីត។ សារធាតុទាំងអស់នេះមានសារធាតុមួយចំនួនគឺយើងត្រូវច្រោះវាយកចេញតាមតម្រង់ ដូចជាសារធាតុទឹក ត្រូវមានតម្រង់ច្រោះវាចេញ ព្រោះវាចូលក្នុងម៉ាស៊ីនមិនបានទេ។ ដូច្នេះយើងត្រូវធ្វើតម្រង់ច្រោះវា។ មានតែកាបូនឌីអុកស៊ីតទេដែលវាចូលទៅឆេះនៅក្នុងម៉ាស៊ីន។ អញ្ចឹងបើសារធាតុណាដែលដុតមិនឆេះ ត្រូវតែច្រោះវាចេញ។ "

ទាក់ទងនឹងការច្រោះឧស្ម័នវិញ លោក អ៊ុន រឿន បានអធិប្បាយថា ត្រូវឆ្លងកាត់ប្រព័ន្ធតម្រង់បួនតំណាក់កាល គឺធុងតម្រង់អង្កាមចំនួន២និងធុងតម្រងអាចម៍រណារចំនួន២ដែលធុងនីមួយៗមានទំហំ ១ ម៉ែត្របួនជ្រុង មុននឹងបន្តចូលទៅកាន់ធុងតម្រងសុវត្ថិភាពរាងជាស៊ីឡាំង ធ្វើអំពីក្រណាត់យ៉ាងក្រាស់ ទំហំប្រមាណ ៣០ ស.ម ដែលជាដំណាក់កាលចុងក្រោយបង្អស់។

"មុននឹងឆ្លងកាត់តម្រងយើងត្រូវដុតកម្តៅពី២០០ទៅ

៨០០ ដឺក្រេ គឺឧស្ម័ននោះក្តៅណាស់ដូច្នេះត្រូវមានតម្រងទឹកមួយ ជួយកាត់បន្ថយកំដៅឱ្យនៅត្រឹមប្រមាណ ៨០ដឺក្រេ ដែលវាអាចឆេះនៅក្នុងម៉ាស៊ីនបាន។ អញ្ចឹងដល់ពេលយើងបើកឧស្ម័ន គឺសារធាតុទាំងអស់នេះវារត់ឆ្លងកាត់ប្រព័ន្ធចម្រោះនីមួយៗដែលមាន អង្កាម និង អាចម៍រណារ ដូចយើងយកខ្សាច់ទៅច្រោះទឹកឱ្យថ្លា អញ្ចឹងដែរ ។ អង្កាមវាធូរ ដូច្នេះឧស្ម័នវាចូលឆ្លងកាត់បាន ប៉ុន្តែធូលីក៏វាងាយស្រួលឆ្លងកាត់បានដែរ ហើយដល់ពេលតម្រងអាចម៍រណារវិញនោះវាហាប់ជាងអង្កាម អញ្ចឹងធូលីមិនងាយឆ្លងកាត់វាបានទេ វាត្រូវជាប់នឹងតម្រងអាចម៍រណារនេះ ហើយរហូតដល់ប្រព័ន្ធចុងក្រោយហ្នឹង គឺគ្មានអ្វីក្រៅពីឧស្ម័នចូលទៅទេ។ " ប៉ុន្តែ លោក អ៊ុន រឿន បានឱ្យដឹងពីសារសំខាន់ពីប្រព័ន្ធចុងតម្រងក្នុង ការធានាគុណភាពឧស្ម័នសម្រាប់ប្រើអូសម៉ាស៊ីនភ្លើងអគ្គិសនី ដែលចាំបាច់គឺត្រូវសំអាតយ៉ាងទៀតទាត់ ហើយលោកបានបញ្ជាក់អំពីរបៀបថែទាំ និងលាងសំអាតចុងតម្រងនីមួយៗដែលមានសេចក្តីលំអិតដូចតទៅនេះ : " អង្កាមសម្បូរដូច្នេះ គឺនៅក្នុង១សប្តាហ៍ ត្រូវសំអាតវាម្តង អាចម៍រណារ ប្រសិនបើយើងសម្បូរគឺយើងផ្លាស់ក្នុងមួយសប្តាហ៍តែបើមិនសម្បូរទេយើងយកវាទៅច្រកថង់កៅស៊ូហាលថ្ងៃឱ្យស្ងួតទៅ យើងអាចយកវាមកប្រើការវិញបាន ហើយប្រព័ន្ធចុងក្រោយ គឺប្រព័ន្ធសុវត្ថិភាពហ្នឹង គេមានក្រណាត់រាងក្រាស់ គេដេរដូចជាថុងទឹករាងជាស៊ីឡាំង ច្រកចូលកន្លែងនេះតែម្តង ហើយក្នុងរយៈពេលមួយថ្ងៃ ឬពីរថ្ងៃត្រូវលាងវា កាលណាបើធូលីមកជាប់ក្រាស់នៅទីហ្នឹងវាអាចស្ទះឧស្ម័នដែលចូលក្នុងម៉ាស៊ីន ។ អញ្ចឹងយើងបោកទឹកលាងវាជាមួយសាប៊ូក៏បាន ឬពេលខ្លះលាងនឹងប្រេងសាំងបើយើងសម្បូរបើយើងក្រ លាងទឹកធម្មតាជាមួយសាប៊ូក៏បានដែរ។" លោក អ៊ុន រឿន បានអធិប្បាយដំណាក់កាលចុងក្រោយ នៃការផលិតភ្លើងអគ្គិសនីជីវម៉ាសនៃគម្រោងអគ្គិសនីជនបទសហគមន៍ភូមិអន្លង់តាម៉ិនេះ ។ " នៅតម្រងសុវត្ថិភាព គឺបើយើងយក ទុយោមួយតចេញពីតម្រងសុវត្ថិភាព និងបំពង់ខ្យល់ ...គឺថា ឱ្យតែ ម៉ាស៊ីនត្រូវតែមានបំពង់ខ្យល់របស់វា ដូចជាម៉ាស៊ីនឡានក៏មានដែរ ដែលគេហៅថា អ៊ែរ គឺបើយើងប្រើប្រេងម៉ាស៊ូត គឺយើងបិទវា ប៉ុន្តែនៅពេលប្រើជាមួយប្រព័ន្ធជីវម៉ាសគឺថាបំពង់ខ្យល់ហ្នឹងហើយ គឺវាស្រូបយកឧស្ម័នហ្នឹងដើម្បីទៅបញ្ឆេះម៉ាស៊ីន ។ កាលណាឧស្ម័នចូលក្នុងបំពង់ខ្យល់យើងបញ្ឆេះគឺវាឆេះតែម្តង ដូចយើងចាក់សាំងដែរ បន្ទាប់មកគឺម៉ាស៊ីនដំណើរការ គឺឌីណាម៉ូវាវិល យើងប្រើជាភ្លើងក៏បាន ជាអ្វីក៏បាន ដូចម៉ាស៊ីនកិនស្រូវគឺវាទាញកញ្ច្រែងកិនអង្ករឱ្យងោក ប៉ុន្តែនៅសហគមន៍អន្លង់តាម៉ិយើងដាក់ឌីណាម៉ូវិញ ហើយពេលឌីណាម៉ូវាវិល គឺវាចេញភ្លើងហើយ ។"

ម៉ាស៊ីនភ្លើងជីវម៉ាសរបស់គម្រោងសហគមន៍អគ្គិសនីជីវម៉ាសអន្លង់តាម៉ិ គឺជាបច្ចេកវិទ្យាដែលនាំមកពីប្រទេសឥណ្ឌាក្នុងឆ្នាំ ២០០៤ ដោយអង្គការ SNE Cambodia ក្រោមថវិកាឧបត្ថម្ភរបស់មូលនិធិកាណាដា និង អង្គការ SNE Cambodia ចំនួន ៤ ម៉ឺនដុល្លារ។ ក្នុងជំហានបន្តបន្ទាប់មកទៀត សហគមន៍បានទទួលថវិកាមួយចំនួនពីអង្គការបរិស្ថានពិភពលោក ដែលផ្តល់តាមរយៈកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ UNDP ប្រចាំកម្ពុជា។ គម្រោងនេះគឺជាកម្មវិធីសាកល្បងដំបូងបង្អស់នៅកម្ពុជា ក្នុងការប្រើប្រាស់ម៉ាស៊ីនភ្លើងអគ្គិសនីជីវម៉ាស ដែលដុតអុសដើមកន្ទុំថេតដែលដាំដោយអ្នកភូមិក្នុងសហគមន៍ផ្ទាល់ជាផ្នែកមួយនៃកិច្ចប្រឹងប្រែងចូលរួមកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិចទៅក្នុងបរិយាកាសនៃភពផែនដី។

ឯកសារយោង :


-ព្រឹត្តិបត្រ ឋបនីយជីវមណ្ឌលបឹងទន្លេសាប លេខ៤ ខែ ធ្នូ ឆ្នាំ ២០០៧

-វិទ្យុសំលេង អាស៊ីសេរី " កិច្ចសម្ភាសន៍របស់អ្នកស្រី កេសរ វុទ្ធីយ៉ា ផ្សាយចេញពីទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក នាខែកុម្ភៈ ២០០៩ "


